# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ: ០១ សរណន**

រាជធានីភ្នំពេញ, ថ្ងៃទី២៥ខែកុម្ភៈ ឆ្នាំ២០០៤

## សារាចរណែនាំ

## ស្តីពី

## ការអនុញ្ញាតអោយរថយន្តចង្កូតស្តាំ និងចង្កូតឆ្វេងគ្រប់ប្រភេទ ដឹកភ្ញៀវទេសចរបរទេសចូលបណ្តោះអាសន្ន និងចេញទៅវិញ ឬ ឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

~~~~~~~~~

កន្លងមក ដោយផ្អែកលើមូលដ្ឋានសន្តិភាព សន្តិសុខ និងសុវត្ថិភាពសាធារណៈនៅទូទាំងប្រទេសមានស្ថិរភាព រាជរដ្ឋាភិបាលបាន និងកំពុងខិតខំជំរុញកិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍យ៉ាងខ្លាំងក្លា ដោយអនុវត្តគោលនយោបាយបើកចំហជើងមេឃ ផ្លូវសមុទ្រ ផ្លូវទន្លេ និង បានបើកច្រកទ្វារព្រំដែនអន្តរជាតិថ្មីៗថែមទៀត ជាមួយបណ្តាប្រទេសជិតខាង ដើម្បីបង្កលក្ខណៈងាយស្រួលដល់លំហូរនៃភ្ញៀវទេសចរបរទេស អោយចូលមកទស្សនាព្រះរាជាណាចក្រកម្ពុជាមានចំនួនកាន់តែកើនឡើងជាលំដាប់ ។

វិស័យទេសចរណ៍បានបង្ហាញយ៉ាងច្បាស់នូវតួនាទីរបស់ខ្លួនជាឧស្សាហកម្មមួយ ដែលមានការលូតលាស់ជាងគេបង្អស់ និងបានក្លាយជាមុខព្រួញយ៉ាងសំខាន់នៃកំលាំងសេដ្ឋកិច្ចតំបន់ ពិភពលោក ក៏ដូចជានៅកម្ពុជាក្នុងពេលបច្ចុប្បន្ន និងពេលអនាគត ។ ចំណូលដែលបានមកពីវិស័យទេសចរណ៍ បានជួយដល់ការអភិវឌ្ឍឿនសេដ្ឋកិច្ចជាតិ តាមរយៈប្រាក់ចំណូលដោយផ្ទាល់ និងប្រាក់ចំណូលដោយប្រយោល ពិសេស គឺឱកាសផ្តល់ការងារដល់ប្រជាពលរដ្ឋ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។

រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ភ្ញៀវទេសចរបរទេសដែលចូលមកទស្សនាព្រះរាជាណាចក្រកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិដោយប្រើមធ្យោបាយរថយន្តចង្កូតស្តាំ និងចង្កូតឆ្វេងគ្រប់ប្រភេទមកកាន់គោលដៅរមណីយ-ដ្ឋានទេសចរណ៍នានា ជាពិសេសការមកទស្សនាប្រាង្គប្រាសាទអង្គរវត្ត ខេត្តសៀមរាប ប្រាង្គប្រាសាទនានា រមណីយដ្ឋានប្រវត្តិសាស្ត្រ ទីវត្តអារាម ឧទ្យានជាតិ ទេសភាព តំបន់ខ្ពង់រាប តំបន់ភ្នំ តំបន់បឹងទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរសមុទ្រ នៃបណ្តាខេត្ត-ក្រុង នៅជួបការលំបាកនៅឡើយ ។
~~~~~~~~~

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរបរទេស និងកែលំអការងារខាងលើ អោយមានភាពរលូនឆាប់រហ័ស រាជរដ្ឋាភិបាលដាក់ចេញនូវការណែនាំ និងវិធានការមួយចំនួនដូចខាងក្រោម :

១-អនុញ្ញាតឱ្យរថយន្តចង្កូតស្តាំ និងចង្កូតឆ្វេងគ្រប់ប្រភេទដឹកភ្ញៀវទេសចរបរទេសចូលបណ្តោះអាសន្ន និងចេញទៅវិញ ឬឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

២-រថយន្តដឹកភ្ញៀវទេសចរបរទេសគ្រប់ប្រភេទ ដែលត្រូវបានអនុញ្ញាតឱ្យចូលបណ្តោះអាសន្ន និងចេញទៅវិញ ឬឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា លុះត្រាតែរថយន្តទាំងនោះបានបំពេញលក្ខខណ្ឌដូចខាងក្រោម :

-មានប័ណ្ណធានារ៉ាប់រងស្របច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា

-មានលក្ខណៈបច្ចេកទេសត្រឹមត្រូវ

-មានផ្លាកលេខសំគាល់ និង

-មានប័ណ្ណសំគាល់រថយន្ត ដែលចេញដោយប្រទេសសាមី ។

៣-អ្នកបើកបររថយន្តដឹកភ្ញៀវទេសចរបរទេស ត្រូវមានប័ណ្ណបើកបរដែលមានសុពលភាពតាមប្រភេទរថយន្ត និងត្រូវមានបទពិសោធន៍ក្នុងការបើកបរប្រកាន់ស្តាំ និងការធ្វើចរាចរក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤-ក្រសួងសាធារណការ និងដឹកជញ្ជូន រៀបចំដាក់ផ្លាកសញ្ញាបង្ហាញផ្លូវ និងចម្ងាយផ្លូវ ពីគោលដៅមួយទៅគោលដៅមួយឱ្យបានច្បាស់លាស់ ចាប់ពីច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកបើកបរដឹកភ្ញៀវទេសចរបរទេសបានស្គាល់ភូមិសាស្ត្រនៃខេត្ត-ក្រុង ស្រុក-ខណ្ឌ ទីប្រជុំជន និងតំបន់ទស្សនកិច្ចសំខាន់ៗ ពេលចូលមកព្រះរាជាណាចក្រកម្ពុជា ។

៥-ម្ចាស់រថយន្តដឹកភ្ញៀវទេសចរបរទេសទាំងអស់ ត្រូវបំពេញបែបបទគយតាមនីតិវិធីជាធរមាន នៅទីស្នាក់ការគយនិងរដ្ឋាករ ប្រចាំនៅច្រកទ្វារព្រំដែនអន្តរជាតិពាក់ព័ន្ធ និងត្រូវយកចេញទៅវិញនូវរថយន្តដែលបានចូលបណ្តោះអាសន្នស្របតាមការអនុញ្ញាត ។

៦-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ជាបន្ទាន់នូវនីតិវិធីគយសាមញ្ញដោយឡែកមួយពាក់ព័ន្ធនឹងបញ្ហានេះដោយកំណត់ឱ្យបានច្បាស់ពីពេលមួយទៅពេលមួយ នូវប្រភេទរថយន្តដែលពុំត្រូវឱ្យកក់ប្រាក់ពន្ធ ឬអាករ ប៉ុន្តែត្រូវអោយមានឯកសារភ្ជាប់នានាសំរាប់ការត្រួតពិនិត្យគយ និង រដ្ឋាករ ការដាក់ឱ្យប្រើប្រាស់នូវប្រតិវេទន៍គយតូច សំរាប់ការចូលបណ្តោះអាសន្ន ឬ ឆ្លងកាត់ ដើម្បីជំរះបញ្ជីពេលរថយន្តចេញទៅវិញ ។

៧-ការខកខានមិនបានយកចេញទៅវិញនូវរថយន្តទាំងនោះ បុគ្គលជាប្រតិវេទករត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងករណីប្រធានស័ក្តិ ។

៨-គ្រប់ភ្នាក់ងារមានសមត្ថកិច្ច ដែលមានភារកិច្ចប្រចាំការនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ត្រូវតែខិតខំជួយសម្រួល ឱ្យភ្ញៀវទេសចរបរទេសចេញ-ចូលព្រះរាជាណាចក្រកម្ពុជា បានកាន់តែងាយស្រួល និងស្របច្បាប់ ។

៩-អភិបាលខេត្ត-ក្រុង ដែលមានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ត្រូវអនុវត្តនូវការធ្វើរបាយការណ៍ អំពីលទ្ធផល នៃបរិមាណយានយន្ត និងភ្ញៀវទេសចរឆ្លងកាត់ច្រកទ្វារចេញ-ចូល មកទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័នពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីខេត្ត-ក្រុង ត្រូវចាត់ចែងអនុវត្តតាមតួនាទីភារកិច្ចរៀងៗខ្លួន ឱ្យទទួលបានលទ្ធផលជាវិជ្ជមាន ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ